# សន្លឹកព័ត៌មាន

AlfredHealth
Carer Services

## សេវាកម្មសម្រាប់អ្នកថែទាំ

### ការផ្គត់ផ្គង់ និងការថែទាំជំនួយបណ្ដោះអាសន្នសម្រាប់អ្នកថែទាំ(២៤ម៉ោង)

*សូមអនុញ្ញាតឱ្យយើងខ្ញុំបានដឹង ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសា។ សេវាកម្មអ្នកថែទាំសុខភាព Alfred មានលទ្ធភាពប្រើប្រាស់អ្នកបកប្រែភាសាតាមទូរស័ព្ទ តាមរយៈ TIS National និង ATIS។*

## ទិដ្ឋភាពទូទៅ

សេវាកម្មអ្នកថែទាំសុខភាព Alfred ផ្ដល់ជូនការផ្គត់ផ្គង់ជាក់ស្តែង និងខាងផ្លូវអារម្មណ៍ សម្រាប់អ្នកថែទាំពេញទូទាំងតំបន់ភាគខាងកើតឆៀងខាងត្បូងនៃទីក្រុងម៉ែលប៊ិន និង Mornington Peninsula។ យើងខ្ញុំក៏ធ្វើការជាមួយសេវាសហគមន៍ផ្សេងទៀតដែរ ដើម្បីជួយពួកគេផ្គត់ផ្គង់អ្នកថែទាំ។

សេវាកម្មនេះគឺជាផ្នែកមួយនៃមជ្ឈមណ្ឌលថែទាំជំនួសបណ្ដោះអាសន្ន Carelink និងសហព័ន្ធ ពេញទូទាំងប្រទេស ហើយទទួលថវិកាផ្គត់ផ្គង់ពីរដ្ឋាភិបាលសហព័ន្ធ និងរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា។

## តើយើងខ្ញុំផ្គត់ផ្គង់នរណាខ្លះ?

យើងខ្ញុំផ្គត់ផ្គង់អ្នកថែទាំ។ អ្នកថែទាំគឺជាមនុស្សម្នាក់ដែលផ្ដល់ការថែទាំដែលគ្មានប្រាក់បៀវត្សរ៍ ហើយផ្គត់ផ្គង់ដល់សមាជិកក្រុមគ្រួសារ ឬមិត្តភក្តិដែលមានភាពពិការ ជំងឺផ្លូវចិត្ត ជំងឺវង្វេងស្មារតី ឬមានវ័យទន់ខ្សោយ។ ការផ្គត់ផ្គង់នេះ អនុញ្ញាតឱ្យបុគ្គលបន្តការរស់នៅតាមផ្ទះ។ អ្នកថែទាំមកពីគ្រប់វណ្ណៈ ពីគ្រប់សញ្ជាតិ និងគ្រប់វ័យ។

អ្នកថែទាំអាចថែទាំរយៈពេលពីរបីម៉ោងក្នុងមួយសប្ដាហ៍ ឬពេញទាំងថ្ងៃ ជារៀងរាល់ថ្ងៃ។ អ្នកថែទាំមួយចំនួនមានសិទ្ធិទទួលប្រាក់បំណាច់របស់រដ្ឋាភិបាល។ អ្នកថែទាំងទៀតត្រូវបានជួល ឬមានប្រាក់ចំណូលឯកជន។

ការថែទាំសម្រាប់អ្នកផ្សេងទៀតអាចស្មុគស្មាញ និងមានតម្រូវការយ៉ាងច្រើន ហើយអ្នកថែទាំណាម្នាក់អាចតម្រូវឱ្យមានជំនួយ និងការផ្គត់ផ្គង់ក្នុងវិធីមួយចំនួនដើម្បីធានាឱ្យបាននូវសុខភាព និងសុខុមាលភាពរបស់ពួកគេ។

> *ម៉ាក់មានភាពទន់ខ្សោយណាស់។ ពេលប៉ាទៅមន្ទីរពេទ្យ យើងត្រូវរៀបចំការផ្គត់ផ្គង់ខ្លះដល់ម៉ាក់ឱ្យបានឆាប់រហ័ស។ ពេលប៉ាបានចេញពីមន្ទីរពេទ្យ គាត់ត្រូវបានបញ្ជូនទៅអ្នកវិជ្ជាជីវៈផ្គត់ផ្គង់អ្នកថែទាំ ហើយពួកគេបានជួយគាត់ដោះស្រាយរឿងផ្សេងៗ។ ឥឡូវនេះប៉ា និងម៉ាក់ យូរៗម្ដងគាត់ទាំងពីរនាក់ទទួលបានជំនួយ និងការសម្រាកមួយចំនួន។*

> *កូនរបស់ខ្ញុំមានជំងឺ autism ជាមួយនឹងការពន្យាពេលធំលូតលាស់ជាទូទៅ។ ពេលពួកយើងបានផ្លាស់ប្ដូរពីរដ្ឋឃ្វីនស្លែន មករស់នៅទីនេះ ខ្ញុំមិនដឹងថាត្រូវចាប់ផ្ដើមពីត្រឹមណាទេដើម្បីស្វែងរកសេវាកម្មក្នុងតំបន់។ បុគ្គលិកសេវាកម្មអ្នកថែទាំសុខភាព Alfred បានជួយពួកយើងដោះស្រាយរឿងផ្សេងៗ។*

## ការថែទាំសម្រាប់អ្នកថែទាំ

តួនាទីរបស់អ្នកថែទាំ អាចមានការហត់នឿយខាងរាងកាយ និងផ្លូវចិត្ត។ ការសម្រាកបានទៀងទាត់ពីកាថែទាំអាចជួយ បន្ធូរការនេះបាន។ ការសម្រាកក៏អាចផ្ដល់ប្រយោជន៍ដល់មនុស្សដែលកំពុងទទួលការថែទាំដែរ។ ការសម្រាកអាចផ្ដល់នូវបទពិសោធន៍ថ្មីៗ និងអ្វីៗដើម្បីទន្ទឹងរង់ចាំទទួល។ ការសម្រាកផ្ដល់នូវឱកាសដើម្បីឯករាជ្យភាព និងការកម្សាន្តមួយចំនួន។ ការសម្រាកទាំងនេះ ជាញឹកញាប់ត្រូវបានគេហៅថាការថែទាំជំនួសបណ្ដោះអាសន្ន ហើយយើងខ្ញុំអាចរៀបចំការនេះជូនបាន។

## ការផ្តល់ផ្តល់សម្រាប់អ្នកថែទាំ

អ្នកវិជ្ជាជីវៈផ្តល់ផ្តល់អ្នកថែទាំ  អាចជួយអ្នកដើម្បីទទួលបានតុល្យភាពរវាងការមើលថែសម្រាប់ខ្លួនអ្នក និងការមើលថែសម្រាប់អ្នកដទៃ។ ការមើលថែសម្រាប់នរណាម្នាក់នៅផ្ទះអាចស្មុគស្មាញ ហើយតម្រូវការយ៉ាងច្រើន។ បុគ្គលិករបស់យើងខ្ញុំយល់ពីស្ថានភាពការមើលថែយ៉ាងជាក់លាក់។ ពួកគេបានយល់ពីតម្រូវការខាងវប្បធម៌ និងបញ្ហាប្រឈមទាំងឡាយដែលអ្នកថែទាំជួបប្រទះ។

ពួកគេគឺជាអ្នកជំនាញផ្នែកសុខភាពដែលមានគុណសម្បត្តិ (ការងារសង្គម ការថែទាំមនុស្សចាស់ ចិត្តវិទ្យា និងសម្ព័ន្ធសុខភាព) ដែលអាចរៀបចំជួបជាមួយអ្នកដើម្បីនិយាយពីសេចក្តីត្រូវការទាំងឡាយ។ ពួកគេដឹងថាស្ថានភាពរបស់មនុស្សម្នាក់ៗ គឺខុសៗគ្នា។

ពួកគេអាចក៏ជួយអ្នកផងដែរដើម្បីរៀបគម្រោងការថែទាំជំនួសបណ្តោះអាសន្ន ហើយការប្រាស្រ័យទាក់ទងជាមួយសេវាផ្សេងៗទៀត។ ពួកគេអាចមានការផ្តល់យោបល់សម្រាប់សុខុមាលភាពរបស់អ្នកផ្ទាល់។ សូមគ្រាន់តែនិយាយជាមួយនរណាម្នាក់អំពីស្ថានភាពរបស់អ្នក នោះក៏អាចមានប្រយោជន៍ដែរ។ មានសេវាកម្មផ្សេងៗដែលមានផ្តល់សម្រាប់មនុស្សដែលនៅក្នុងប្រភេទផ្សេងគ្នានៃស្ថានភាពការថែទាំ។

## យើងខ្ញុំធ្វើការជាមួយអ្នក

ការសម្រេចចិត្តមួយចំនួនដែលអ្នកធ្វើក្នុងឋានៈជាអ្នកថែទាំ អាចមិនមានភាពងាយស្រួល ក៏ប៉ុន្តែអ្នកមិនគួរមានអារម្មណ៍ថាលែងគ្រប់គ្រងបាន ឬនៅក្រោមសម្ពាធនោះឡើយ។ យើងខ្ញុំអាចជួយអ្នកក្នុងការស្វែងរកជម្រើសរបស់អ្នក។

## ចុះប្រសិនបើខ្ញុំមានសេចក្តីត្រូវការពិសេសដោយសារតែភាសា ឬវប្បធម៌របស់ខ្ញុំ?

យើងខ្ញុំផ្តល់ផ្តល់អ្នកថែទាំមកពីសាវតាខុសៗគ្នា។  យើងខ្ញុំអាចរៀបចំអ្នកបកប្រែភាសាដើម្បីនិយាយជាមួយអ្នកតាមទូរស័ព្ទ ឬមុខទល់នឹងមុខ។ ធនធានរបស់យើងខ្ញុំជាច្រើនមានផ្តល់ជាភាសាផ្សេងពីភាសាអង់គ្លេស។ យើងខ្ញុំអាចភ្ជាប់អ្នកទៅនឹងក្រុមគាំទ្រអ្នកថែទាំដែលមានវប្បធម៌ផ្សេងគ្នានៅក្នុងសហគមន៍។

**ទាក់ទង សេវាកម្មអ្នកថែទាំសុខភាព  Alfred**

**ទូរស័ព្ទឥតគិតថ្លៃ  *1800 052  222**

* (ទូរស័ព្ទឥតគិតថ្លៃ លើកលែងទូរស័ព្ទចេញពីទូរស័ព្ទដៃ)

សេវាអ្នកបកប្រែភាសាមានផ្តល់ជូនតាមការស្នើសុំ ឬទូរស័ព្ទទៅ
សេវាអ្នកបកប្រែភាសាតាមទូរស័ព្ទ **131 450**

មានដំណោះស្រាយតាមទូរស័ព្ទ សម្រាប់មនុស្សថ្លង់ ឬពិការភាពក្នុងការស្តាប់ ឬនិយាយ
សេវា **National Relay Service 1800 555 660**

May 2015